7-19-2019

# ប្រតិកម្មរបស់តំណាងរាស្ត្រអឺរ៉ុបជុំវិញការបិទទិដ្ឋាការមិនឱ្យអមដំណើរ លោក សម រង្ស៊ី មកកម្ពុជា



*តំណាងរាស្ត្រសភាអឺរ៉ុប លោក ហ្វីល ប៉ែននៀន (Phil Bennion) (ស្តាំ)។*

ដោយ មាន ឬទ្ធិ
**2019-07-18**

*សមាជិកសភាអឺរ៉ុបមកពីចក្រភពអង់គ្លេសលោក ហ្វីល ប៉ែននៀន (Phil Bennion) ដែលធ្លាប់សន្យាជាសាធារណៈថា លោកនឹងអមដំណើរលោក សម រង្ស៊ី ប្រធានស្តីទីគណបក្សសង្គ្រោះជាតិ ធ្វើមាតុភូមិនិវត្តមកកាន់កម្ពុជាវិញ ប្រាប់អាស៊ីសេរីតាមសារអេឡិចត្រូនិកកាលពីថ្ងៃទី១៧ កក្កដា ថា ករណីរបបលោក ហ៊ុន សែន ដាក់បញ្ចូលឈ្មោះលោក ទៅក្នុងបញ្ជីបដិសេធផ្តល់ទិដ្ឋាការឱ្យចូលកម្ពុជានោះ រឹតតែស្តែងឱ្យឃើញថា កម្ពុជាបានដកខ្លួនចេញឆ្ងាយពីលទ្ធិប្រជាធិបតេយ្យសេរីពហុបក្ស និងការគោរពសិទ្ធិមនុស្ស។ លោកសង្កត់ធ្ងន់ៗថា ការធ្វើដូច្នេះ នឹងរឹតតែពង្រឹងឱ្យមាននូវការអំពាវនាវកាន់តែខ្លាំងឡើងថែមទៀត ឱ្យមានចំណាត់ការប្រឆាំងនឹងកម្ពុជា និងរដ្ឋាភិបាលនៃប្រទេសមួយនេះ ដែលបានធ្វើទង្វើអកុសលទាំងនេះ។*

*កាលពី១៥ កក្កដា លោក ប្រាក់ សុខុន រដ្ឋមន្ត្រីក្រសួងការបរទេស បានសរសេរលិខិតមួយច្បាប់ បញ្ជាឱ្យមន្ត្រីឯកអគ្គរាជទូត អគ្គកុងស៊ុល និងកុងស៊ុលកិត្តិយសរបស់ខ្លួននៅបរទេសទាំងអស់ ធ្វើការបដិសេធ ឬកុំផ្តល់ទិដ្ឋាការដល់ជនបរទេសទាំងឡាយណា ដែលរបបនេះថា មានបំណងគាំទ្រ ឬការពារជនណាផ្តន្ទាទោស ឬកំពុងជាប់ទោស*

ដោយសាលដីកាតុលាការកម្ពុជា។ លោក ប្រាក់ សុខុន ស្នើឱ្យមន្ត្រីក្រោមឱវាទរបស់លោកទាំងនោះ ពិនិត្យមើលឱ្យបានហ្មត់ចត់ និងច្បាស់លាស់ពីគោលបំណងរបស់ជនបរទេសដែលស្នើសុំទិដ្ឋាការចូលកម្ពុជាទាំងនោះ ក្នុងអ្វីមួយដែលលោកថា ដើម្បីជានាសន្តិសុខ និងសុវត្ថិភាព ក៏ដូចជាការពារអធិបតេយ្យកម្ពុជា។ លិខិតនោះ ក៏មានភ្ជាប់មកជាមួយនូវបញ្ជីឈ្មោះ អមដោយថ្ងៃខែឆ្នាំកំណើត និងរូបថតរបស់សមាជិកសភាអឺរ៉ុប ៤រូប
អតីតសមាជិកសភាអឺរ៉ុបម្នាក់ និង អនុប្រធាន ចលនាសេរីនិយមអន្តរជាតិ (Liberal International) ។

មន្ត្រីស្ថានឯកអគ្គរាជទូតកម្ពុជាប្រចាំចក្រភពអង់គ្លេសមួយរូប សុំមិនបញ្ចេញឈ្មោះ ប្រាប់អាស៊ីសេរីតាមទូរស័ព្ទបញ្ជាក់ថា ស្ថានទូតបានទទួលលិខិតពីលោក ប្រាក់ សុខុនមែន។

ថ្វីបើមានការបញ្ជាពីរបបក្រុងភ្នំពេញយ៉ាងដូច្នេះក៏ដោយ កន្លងមកពាក់ព័ន្ធនឹងសំណុំរឿងជាមួយលោក សម រង្ស៊ី របបនេះមិនដែលហ៊ានស្នើសុំប្រទេសបារាំងជាផ្លូវការឱ្យធ្វើបត្យាប័ន ឬចាប់បញ្ជូនខ្លួនលោក សម រង្ស៊ី មកទទួលទោសទណ្ឌនៅកម្ពុជាឡើយ បើទោះជាកម្ពុជា និងបារាំងមានកិច្ចព្រមព្រៀងបត្យាប័នយ៉ាងណាក៏ដោយ៕